

## ការពិត

# តើមេរោគ HIV (វីរុសបង្កឱ្យកើតជំងឺអេដស៍) គឺជាអ្វី?

Khmer | ខ្មែរ

# តើមេរោគ HIV គឺជាអ្វី?

មេរោគ HIV ឬ វីរុសបង្កឱ្យកើតជំងឺអេដស៍ គឺជាវីរុសដែលធ្វើឱ្យប្រព័ន្ធភាពស៊ាំចុះខ្សោយ។ វាបំផ្លាញកោសិកានានាដែលហៅថាកោសិកា CD4 ដែលប្រឆាំងនឹងការឆ្លងមេរោគ និងជំងឺ។ ការបំផ្លាញនេះធ្វើឱ្យរាងកាយពិបាកក្នុងការប្រយុទ្ធប្រឆាំងនឹងការឆ្លងមេរោគផ្សេងៗ។ មេរោគ HIV ក៏ប្រើកោសិកា CD4 ដើម្បីចម្លងខ្លួនឯងបន្ថែមទៀត ហើយឆ្លងទៅកោសិកា CD4 ផ្សេងទៀតផងដែរ។ គ្មានឱសថព្យាបាលមេរោគ HIV ឱ្យជាស្រឡះបាននោះទេ ប៉ុន្តែការព្យាបាលមានប្រសិទ្ធភាពខ្លាំង ហើយអាចរក្សាអ្នកឱ្យមានសុខភាពល្អ។

### *មេរោគ HIV មិនមែនជាជំងឺអេដស៍ទេ*

មេរោគ HIV និងជំងឺអេដស៍គឺខុសគ្នា។ មេរោគ HIV គឺជាវីរុសមួយដែលអាចឈានទៅដល់កើតជំងឺអេដស៍ ប្រសិនបើមិនបានព្យាបាលវា។ ពេលណាមិនបានព្យាបាលមេរោគ HIV ទេនោះ ប្រព័ន្ធភាពស៊ាំចុះខ្សោយខ្លាំង ហើយបណ្តាលឱ្យមានការឆ្លងធ្ងន់ធ្ងរ។ ដំណាក់កាលនៃការឆ្លងមេរោគ HIV ដែលមិនបានព្យាបាលត្រូវបានគេហៅថា រោគសញ្ញាជំងឺកង្វះភាពស៊ាំដែលទទួលបានបន្ទាប់ពីឆ្លងរោគ ឬជំងឺអេដស៍ (AIDS)។ នៅប្រទេសអូស្ត្រាលី ជំងឺអេដស៍គឺកម្រមានណាស់ ពីព្រោះយើងមានការព្យាបាលមេរោគ HIV យ៉ាងមានប្រសិទ្ធភាព។ ជំងឺអេដស៍អាចកើតមានឡើង ប្រសិនបើនរណាម្នាក់កំពុងរស់នៅមានផ្ទុកមេរោគ HIV រយៈពេលយូរ មុនពេលពួកគេត្រូវបានធ្វើរោគវិនិច្ឆ័យ ឬប្រសិនបើពួកគេមិនទទួលការព្យាបាល។

### *ដោយមានការព្យាបាល មនុស្សកំពុងរស់នៅមានផ្ទុកមេរោគ HIV អាចរស់នៅបានយូរ និងមានសុខភាពល្អ*

មនុស្សកំពុងរស់នៅមានផ្ទុកមេរោគ HIV អាចរស់នៅបានយូរ និងមានសុខភាពល្អ ប្រសិនបើពួកគេទទួលការព្យាបាលមេរោគ HIV។ ការចាប់ផ្តើមព្យាបាលភ្លាមៗបន្ទាប់ពីបានធ្វើរោគវិនិច្ឆ័យថាមានផ្ទុកមេរោគ HIV ធ្វើឱ្យសុខភាពរបស់អ្នកប្រសើរឡើងក្នុងរយៈពេលវែង។ ការព្យាបាលរារាំងមេរោគ HIV ពីការចម្លងខ្លួនឯងបន្ថែមទៀត ដែលជួយរក្សាមនុស្សឱ្យមានសុខភាពល្អ និងបញ្ឈប់ការចម្លងមេរោគ HIV។

## *អ្នកមិនឯកោទេ*

នៅឆ្នាំ 2021៖

- នៅទូទាំងពិភពលោក មនុស្សប្រហែល 38.4 លាននាក់ កំពុងរស់នៅមានផ្ទុកមេរោគ HIV
- នៅប្រទេសអូស្ត្រាលី មនុស្សប្រហែល 29 500 នាក់ កំពុងរស់នៅមានផ្ទុកមេរោគ HIV
- ក្នុងចំណោមប្រជាជននៅប្រទេសអូស្ត្រាលី 88% ជាបុរស ហើយ 12% ជាស្ត្រី
- នៅប្រទេសអូស្ត្រាលី 98% នៃអ្នកទទួលការព្យាបាល ត្រូវបានព្យាបាលយ៉ាងមានប្រសិទ្ធភាព ដែលមានន័យថាពួកគេមិនអាចចម្លងមេរោគ HIV ទៅដៃគូរបស់ពួកគេបានឡើយ។
- នៅរដ្ឋវិចថូរៀ មនុស្សប្រហែល 9 400 នាក់ កំពុងរស់នៅមានផ្ទុកមេរោគ HIV

## *ការធ្វើតេស្តមេរោគ HIV និងអំឡុងពេលដែលបានឆ្លងមេរោគដំបូង និងការទទួលលទ្ធផលតេស្ត*

រយៈពេលរវាងការឆ្លងមេរោគ HIV និងការបង្ហាញមេរោគ HIV នៅក្នុងការធ្វើតេស្ត ត្រូវបានគេហៅថាអំឡុងពេលដែលបានឆ្លងមេរោគដំបូង និងការទទួលលទ្ធផលតេស្ត។ ការធ្វើតេស្តឈាមរកមើលមេរោគ HIV នៅក្នុងប្រទេសអូស្ត្រាលី ត្រូវគិតចាប់ពីពេលដែលបានឆ្លងរោគដំបូង រហូតដល់ថ្ងៃធ្វើតេស្តឈាម ត្រូវមានរយៈពេល6សប្តាហ៏ ដែលមានន័យថា លទ្ធផលឈាមដែលត្រឹមត្រូវគឺគិតចាប់ពី6សប្តាហ៏បន្ទាប់ពីការឆ្លងមេរោគ។ ដូច្នេះ ប្រសិនបើលទ្ធផលតេស្តឈាមរបស់អ្នកអវិជ្ជមាន ហើយអ្នកទើបតែបានប៉ះពាល់ជាមួយមេរោគនេះរយៈពេលតិចជា6សប្តាហ៏ អ្នកគួរតែធ្វើតេស្តឈាមមួយទៀតនៅរយៈពេល៦សប្តាហ៏ក្រោយមក ដើម្បីឱ្យមានភាពប្រាកដច្បាស់លាស់។ អំឡុងពេលដែលបានឆ្លងមេរោគដំបូង និងការទទួលលទ្ធផលតេស្ត សម្រាប់ការធ្វើតេស្តនៅផ្ទះអាចមានរហូតដល់ទៅ 12 សប្តាហ៍។

## ដំណាក់កាលនៃការឆ្លងមេរោគ HIV (ដោយគ្មានការព្យាបាល)

មនុស្សកំពុងរស់នៅមានផ្ទុកមេរោគ HIV ជាធម្មតាមិនមានរោគសញ្ញាភ្លាមៗទេ។ វាអាចចំណាយពេលច្រើនឆ្នាំសម្រាប់បុគ្គលកំពុងរស់នៅមានផ្ទុកមេរោគ HIV មុនចេញរោគសញ្ញានានា។

ដោយគ្មានការព្យាបាលទេនោះ មនុស្សកំពុងរស់នៅមានផ្ទុកមេរោគ HIV នឹងឆ្លងកាត់ដំណាក់កាលនានាដូចខាងក្រោម៖

### *ដំណាក់កាលស្រួចស្រាវ (ការឆ្លងមេរោគ HIV ដំបូង)*

ដំណាក់កាលស្រួចស្រាវ គឺជាពេលវេលារវាងមេរោគ HIV ចូលទៅក្នុងរាងកាយ និងប្រព័ន្ធភាពស៊ាំបង្កើតអង្គបដិប្រាណដើម្បីប្រយុទ្ធប្រឆាំងនឹងវា។ មនុស្សមួយចំនួននឹងមានរោគសញ្ញាដូចជំងឺគ្រុនផ្តាសាយ 1 ទៅ 4 សប្តាហ៍ បន្ទាប់ពីឆ្លងមេរោគ HIV។ នេះត្រូវបានគេហៅថាជំងឺ seroconversion (ការផ្លាស់ប្តូរពីចំណុចនៃការឆ្លងវីរុស ទៅពេលដែលអង្គបដិប្រាណនៃមេរោគមានវត្តមានក្នុងឈាម) ហើយជាធម្មតាមានរយៈពេលត្រឹមតែ 1 ទៅ 2 សប្តាហ៍ប៉ុណ្ណោះ។

រោគសញ្ញានានាអាចរួមមាន៖

- គ្រុនក្តៅ
- បែកញើសនៅពេលយប់
- ឈឺសាច់ដុំ
- ហើមកូនកណ្តុរ (ក្រោមដៃ ក្រលៀន និងក)
- ឈឺបំពង់ក
- កន្ទួល

មនុស្សខ្លះមិនមានរោគសញ្ញាអ្វីទាំងអស់។

មនុស្សភាគច្រើនមិនដឹងថាពួកគេបានឆ្លងមេរោគ HIV ក្នុងដំណាក់កាលស្រួចស្រាវនោះទេ។ ក្នុងដំណាក់កាលនេះ បរិមាណនៃមេរោគ HIV ក្នុងឈាមគឺមានកម្រិតខ្ពស់ណាស់ ដូច្នេះហានិភ័យនៃមេរោគ HIV ដែលអាចចម្លងទៅអ្នកផ្សេងទៀតក៏មានកម្រិតខ្ពស់ផងដែរ។

***ដំណាក់កាលរ៉ាំរ៉ៃ (ការឆ្លងមេរោគ HIV ដោយគ្មានរោគសញ្ញា)***

បន្ទាប់ពីដំណាក់កាលស្រួចស្រាវ មនុស្សភាគច្រើនមានអារម្មណ៍ដូចជាពួកគេត្រឡប់មកសុខភាពធម្មតាវិញ។ សម្រាប់មនុស្សមួយចំនួន ដំណាក់កាលរ៉ាំរ៉ៃនេះអាចមានរយៈពេលជាងដប់ឆ្នាំ។ សម្រាប់អ្នកផ្សេងទៀត អាចមានរយៈពេលខ្លីជាង។ ទោះបីជាមនុស្សមិនមានរោគសញ្ញាធ្ងន់ធ្ងរក៏ដោយ មេរោគ HIV នៅតែសកម្មនៅក្នុងរាងកាយ បំផ្លាញប្រព័ន្ធភាពស៊ាំ និងបង្កើតការចម្លងខ្លួនឯង។

## ដំណាក់កាលនៃការមិនបានព្យាបាលមេរោគ HIV



## ជំងឺដែលកំណត់អត្តសញ្ញាណជំងឺអេដស៍

មេរោគ HIV បំផ្លាញប្រព័ន្ធភាពស៊ាំទៅតាមពេលវេលា និងបង្កើនហានិភ័យនៃជំងឺធ្ងន់ធ្ងរ។ នេះអាចរួមមានជំងឺមហារីក ជំងឺបេះដូង ការខូចថ្លើម និងតម្រងនោម។ ផលប៉ះពាល់ផ្សេងទៀតអាចរួមមានការស្រកទម្ងន់ រាគរូស អស់កម្លាំង រោគជ្រាំង ការឈឺសន្លាក់ បញ្ហាស្បែក និងការរលាកស្ងួតដោយបាក់តេរី។ មេរោគ HIV ក៏អាចប៉ះពាល់ដល់ខួរក្បាល និងការចងចាំផងដែរ។ ប្រសិនបើចំនួនកោសិកា CD4 ដែលមានសុខភាពល្អធ្លាក់ចុះកម្រិតទាបពេក ហើយបរិមាណនៃមេរោគ HIV ក្នុងឈាមកើនឡើង មនុស្សចាប់ផ្តើមកើតមានការឆ្លងធ្ងន់ធ្ងរ ឬកើតទៅជាជំងឺមហារីកដែលកម្រកើតមានចំពោះអ្នកមិនមានផ្ទុកមេរោគ HIV។ ទាំងនេះត្រូវបានគេហៅថាជំងឺដែលកំណត់អត្តសញ្ញាណជំងឺអេដស៍។ សូម្បីតែក្នុងដំណាក់កាលនេះក្តី ការព្យាបាលមេរោគ HIV នៅតែមានប្រសិទ្ធភាព ហើយមនុស្សអាចមានសុខភាពល្អឡើងវិញបាន។

## ចុះបើខ្ញុំកំពុងទទួលការព្យាបាល?

ការព្យាបាលមេរោគ HIV មានប្រសិទ្ធភាពណាស់។ ប្រសិនបើអ្នកទទួលយកការព្យាបាលរបស់អ្នកតាមវេជ្ជបញ្ជាដែលធ្វើឡើងដោយវេជ្ជបណ្ឌិតរបស់អ្នក អ្នកនឹងមានផ្ទុកមេរោគ HIV ក្នុងឈាមរបស់អ្នកកម្រិតទាបបំផុត អ្នកទំនងជាមិនមានរោគសញ្ញា ឬចម្លងមេរោគ HIV ទេ ហើយអ្នកអាចរស់នៅបានយូរ និងមានសុខភាពល្អ។

## សម្រាប់ព័ត៌មានបន្ថែម

living positive victoria

ViiV Healthcare